01629833

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារ D266/12

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣៥)

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន |
| | ចៅក្រម Olivier BEAUVALLET |
| | ចៅក្រម និយ ថុល |
| | ចៅក្រម Kang Jin BAIK |
| | ចៅក្រម ហួត វុទ្ធី |
| កាលបរិច្ឆេទ: | ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 10 / 2019
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សាធារណៈ:

# ដីកាកំណត់កាលវិភាគសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ

**សហព្រះរាជអាជ្ញា**

ជា លាង
Brenda HOLLIS

**សហមេធាវីការពារក្តី មាស មុត**

អាង ឧត្តម
Michael G. KARNAVAS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Philippe CANONNE

Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

01629834



**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**បានទទួល**បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ[១] និងសហមេធាវីការពារក្តី មាស មុត[២] នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ និងថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ប្រឆាំងនឹងដីកាដំណោះស្រាយដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅក្នុងសំណុំរឿង ០០៣[៣] និងបណ្តឹងឧទ្ធរណ៍ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩[៤] ប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់សំណុំរឿងប្រឆាំង មាស មុត ដែលសហចៅក្រមស៊ើបអង្កេតជាតិបានចេញនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅក្នុងសំណុំរឿង ០០៣[៥]។

**យល់ឃើញ**ថា សារណាបណ្តឹងឧទ្ធរណ៍នៅក្នុងសំណុំរឿងនេះបានដាក់ចប់សព្វគ្រប់ហើយ។

**បានឃើញ** សារណានានាពាក់ព័ន្ធនឹងសវនាការ ក្នុងការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩[៦] ដែលបានដាក់ដោយសហមេធាវីការពារក្តី មាស មុត[៧] នៅថ្ងៃទី

---

[១] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៣") បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/3។

[២] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/4។

[៣] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267។

[៤] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D266/2។

[៥] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266។

[៦] សំណុំរឿង ០០៣ ការជូនដំណឹងរបស់អង្គបុរេជំនុំជម្រះដល់ភាគីតាមរយៈអ៊ីមែល ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ៣:៣៣ នាទីរសៀល។

[៧] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងរបស់ មាស មុត អំពីចេតនាចូលរួមក្នុងសវនាការទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D266/8 និង D267/13។

១១ ខែកញ្ញា ឆ្នាំ២០១៩ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[៨] នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ និង ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ[៩] នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។

**បានឃើញ** សេចក្តីជូនដំណឹងរបស់ មាស មុត អំពីចេតនាអនុវត្តសិទ្ធិនៅស្ងៀម និង លះបង់សិទ្ធិចូលរួមក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ ដែលសហមេធាវីការពារក្តី មាស មុត បានដាក់នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩[១០]។

**អនុលោមតាម**វិធាន ៧៧(៣), ៧៧(៥) និង ៧៧(៦) នៃវិធានផ្ទៃក្នុង។

**តនៅនេះបង្គាប់** ថា សវនាការនឹងត្រូវធ្វើឡើងនៅក្នុងបន្ទប់សវនាការនៅថ្ងៃពុធ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ថ្ងៃព្រហស្បតិ៍ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ និង ថ្ងៃសុក្រ ទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩។ និង

**ជូនដំណឹង** ដល់ភាគីថា កាលវិភាគសម្រាប់សវនាការមានដូចខាងក្រោម៖

**ថ្ងៃពុធ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩÷**

| | |
|---|---|
| ម៉ោង ៩:៣០ - ៩:៤៥ | បើកសវនាការ (១៥ នាទី) |
| ម៉ោង ៩:៤៥ - ១០:១៥ | ការរាយការណ៍អំពីសំណុំរឿងដោយអង្គជំនុំជម្រះ (៣០ នាទី) |
| ម៉ោង ១០:១៥ - ១១:១៥ | បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (១ ម៉ោង) |
| ម៉ោង ១១:១៥ - ១២:៤៥ | *ផ្អាកសវនាការ (១ ម៉ោង កន្លះ)* |
| ម៉ោង ១២:៤៥ - ១៦:១៥ | បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (៣ ម៉ោង កន្លះ) |

---

[៨] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះដល់ភាគីទាក់ទងនឹងសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ និងបានដាក់នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D266/9 និង D267/14។

[៩] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះដល់ភាគីទាក់ទងនឹងសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D266/10 និង D267/15។

[១០] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងរបស់ មាស មុត អំពីចេតនាអនុវត្តសិទ្ធិនៅស្ងៀម និង លះបង់សិទ្ធិចូលរួមក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ឯកសារ D266/11 និង D267/16។

សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣៥)

ឯកសារលេខ **D266/12**

**ថ្ងៃព្រហស្បតិ៍ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩៖**

ម៉ោង ០៩:៣០ - ១២:០០ បណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីជាតិ/អន្តរជាតិ (២ ម៉ោង កន្លះ)

ម៉ោង ១២:០០ - ១៣:៣០ *ផ្អាកសវនាការ (១ ម៉ោង កន្លះ)*

ម៉ោង ១៣:៣០ - ១៥:៣០ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (២ ម៉ោង)

**ថ្ងៃសុក្រ ទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩៖**

ម៉ោង ០៩:៣០ - ១១:០០ ចម្លើយតបរបស់មេធាវីការពារក្ដីជាតិ/អន្តរជាតិ (១ ម៉ោង កន្លះ)

ម៉ោង ១១:០០ - ១២:៣០ ចៅក្រមសាកសួរភាគី ប្រសិនបើមានភាពចាំបាច់។ ផ្ដល់ការជូនដំណឹង និងព័ត៌មានពាក់ព័ន្ធ នៅថ្ងៃព្រហស្បតិ៍ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ (១ ម៉ោង កន្លះ)

**បង្គាប់**ថា សហមេធាវីការពារក្ដីត្រូវដាក់សំណើសុំជូនអង្គជំនុំជម្រះ បញ្ជាក់ពីភាពមិនចាំបាច់នៃការបង្ហាញខ្លួនផ្ទាល់របស់ជនត្រូវចោទ ដោយបង្ហាញយុត្តិកម្មឲ្យបានពេញលេញ។

**ជូនដំណឹង**ថា ក្នុងករណីចាំបាច់ តុលាការអាចរៀបចំប្រព័ន្ធសោតទស្សន៍សម្រាប់ការចូលរួមសវនាការរបស់ជនត្រូវចោទ។ និង

**សម្រេច**ថា សវនាការនឹងត្រូវធ្វើឡើងជាសាធារណៈនៅពេលចាប់ផ្ដើម ការរាយការណ៍ពីសំណុំរឿងដោយអង្គជំនុំជម្រះ និងការសាកសួររបស់ចៅក្រមចំពោះភាគី។ ផ្នែកផ្សេងទៀតនៃសវនាការនឹងធ្វើឡើងជា*អសាធារណៈ*។

**រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩**

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**